ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកវគ្គសុក្រឹតការ ជំនាន់ទី១២
# នៅធនាគារជាតិនៃកម្ពុជា
# ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧

**ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងសិក្ខាកាម ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីបើកវគ្គសុក្រឹតការជំនាន់ទី១២ នាពេលនេះ។ នេះគឺជាវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសធនាគារកណ្តាលសម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលយើងបានរៀបចំបន្ថែមទៀត ដោយខ្លួនឯងទាំងកម្មវិធីបណ្តុះបណ្តាល ការរៀបចំឯកសារ និងការបណ្តុះបណ្តាល នៅក្នុងឆ្នាំ២០១៧នេះ និងបានធ្វើបច្ចុប្បន្នកម្មនៃកម្មវិធីបណ្តុះបណ្តាលឲ្យកាន់តែប្រសើរ និងឆ្លើយតបទៅនឹងតម្រូវការការងារជាក់ស្តែង។ ដូចលោកប្រធាននាយកដ្ឋានបុគ្គលិក បានជម្រាបជូនក្នុងរបាយការណ៍រួចហើយថា វគ្គសុក្រឹតការនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងឲ្យមន្ត្រីបុគ្គលិកជាសិក្ខាកាមបានយល់ច្បាស់អំពីបច្ចេកទេស និងក្របខ័ណ្ឌការងាររបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសអំពីមុខងារភារកិច្ចស្នូលក្នុងការសម្រេចគោលដៅនយោបាយ និងគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចជាតិ ដែលកំពុងមានការកោតសរសើរយ៉ាងខ្លាំងជុំវិញមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកនេះ ប្រព័ន្ធធនាគាររបស់យើងបានរីកចម្រើនគួរឲ្យកត់សម្គាល់។ ការអភិវឌ្ឍរីកចម្រើននេះ គឺទាមទារឲ្យធនាគារជាតិនៃកម្ពុជាយើងដែលជាអាជ្ញាធររូបិយវត្ថុ និងអាជ្ញាធរលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្លាយជាស្ថាប័នមួយប្រកបដោយការគោរពនិងជឿជាក់ពីសំណាក់សាធារណជន តាមរយៈ សុច្ចរិតភាព សមត្ថភាព និងការបំពេញភារកិច្ចស្នូលអំពីការអនុវត្តគោលនយោបាយរូបិយវត្ថុ ការរក្សាសុវត្ថិភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងទីផ្សារប្តូរប្រាក់និងទុនបំរុងអន្តរជាតិ ការគ្រប់គ្រងប្រព័ន្ធទូទាត់និងបោះផ្សាយរូបិយវត្ថុជាតិ និងការផ្តល់សេវាជូនរាជរដ្ឋាភិបាលនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ល។និង។ល។

ឆ្លើយតបទៅនឹងការអភិវឌ្ឍរីកចម្រើនឥតឈប់ឈរនេះ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍទាំងសមត្ថភាពធនធានមនុស្ស សមត្ថភាពស្ថាប័ន និងក្របខ័ណ្ឌច្បាប់បានយ៉ាងល្អប្រសើរ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាយើងបានធ្វើការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកគ្រប់រូបភាពទាំងក្នុងនិងក្រៅប្រទេសបានយ៉ាងល្អ និងមានការកោតសសើរពីសំណាក់ស្ថាប័នអន្តរជាតិថែមទៀត។ ចំពោះការអភិវឌ្ឍសមត្ថភាពស្ថាប័នវិញ គឺយើងបានសាងសង់អគារថ្មីៗនៅតាមបណ្តាសាខារាជធានី-ខេត្ត បង្កើតទីកន្លែងការងារប្រកបដោយផាសុខភាព និងបំពាក់ប្រព័ន្ធពត៌មានវិទ្យានិងប្រព័ន្ធសុវត្ថិភាពបានយ៉ាងល្អត្រឹមត្រូវ។ យើងក៏បានត្រៀមសាងសង់អគារធនាគារជាតិនៃកម្ពុជានៅបំណាច់ឆ្នាំនេះផងដែរ ដើម្បីបង្កើតបរិយាកាសការងាល្អជូនមន្ត្រីបុគ្គលិកផង និងដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃសង្គមជាតិយើងផង។

ទន្ទឹមនឹងនេះ យើងក៏បានអភិវឌ្ឍក្របខ័ណ្ឌច្បាប់ជាបន្តបន្ទាប់ ដូចជា ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា នៅឆ្នាំ១៩៩៦ ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ នៅឆ្នាំ១៩៩៧ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅឆ្នាំ១៩៩៩ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ នៅឆ្នាំ២០០៥ ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅឆ្នាំ២០០៧ ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុនៅឆ្នាំ២០០៩ និងបទប្បញ្ញត្តិផ្សេងៗសម្រាប់ជាមូលដ្ឋានគតិយុត្តដ៏សំខាន់ ដើម្បីឲ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបំពេញភារកិច្ចខ្លួនឲ្យបានខ្ជាប់ខ្ជួននិងមានប្រសិទ្ធភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតនៅក្នុងឱកាសនេះដែរ ខ្ញុំសូមផ្តល់នូវទស្សនៈមួយចំនួនដើម្បីជាដើមទុនសម្រាប់សិក្ខាកាមពិចារណានៅក្នុងការអនុវត្តការងារប្រចាំថ្ងៃ។ បើយើងងាកទៅមើលប្រវត្តិសាស្ត្រធនាគារកណ្តាលដំបូងគេ ត្រូវបានបង្កើតឡើងនៅប្រទេសអង់គ្លេសក្នុងឆ្នាំ១៦៩៥។ ក្រោយមកនៅសតវត្សរ៍ទី១៩ ប្រទេសជាច្រើននៅអឺរ៉ុបក៏បានបង្កើតឲ្យមានធនាគារកណ្តាលរបស់ខ្លួន និងបានបំពេញកាតព្វកិច្ចជាពិសេសសម្រាប់រដ្ឋ ពោលគឺ ហិរញ្ញប្បទានឲ្យសង្គ្រាម ឬផ្តល់លុយកាក់ចវិកាបម្រើឲ្យសង្គ្រាម។ ដោយសារមុខងារនេះហើយ ធនាគារកណ្តាលទាំងនោះក៏បានទទួលពីរដ្ឋមកវិញនូវបុព្វសិទ្ធិដ៏ពិសេសមួយ គឺការបោះពុម្ពនិងបោះផ្សាយនូវធនបត្រដែលភាសាសាមញ្ញហៅថា " **ក្រដាសប្រាក់** "។

តាមរយៈបុព្វសិទ្ធិដ៏ពិសេសនេះ ធនាគារកណ្តាលដែលជាធនាគាររបស់រដ្ឋ ក៏បានរកឃើញដោយខ្លួនឯងថា ពួកគេគួរបានបំពេញនូវតួនាទីភារកិច្ចថ្មីមួយទៀត គឺជាធនាគាររបស់បណ្តាធនាគារ។ ដោយហេតុថា ធនាគារពាណិជ្ជដែលទទួលបញ្ញើទាំងអស់ (នៅពេលនោះជាមាសក្តីជាក្រដាសប្រាក់ក្តី) ត្រូវពឹងពាក់អាស្រ័យទៅលើធនាគារណាមួយដែលបោះផ្សាយក្រដាសប្រាក់។ ក្នុងពេលនោះដែរ ក្រដាសប្រាក់បានដើរទន្ទឹមគ្នាជាមួយនឹងមាស ដែលទាំង២មុខនេះ ជាប្រភពសំខាន់នៃសន្ទនីយភាពនៅក្នុងសេដ្ឋកិច្ច ហើយពួកអ្នកផ្ញើទាំងឡាយតែងតែត្រូវការដកយកមកប្រើប្រាស់គ្រប់ពេលវេលា។ នៅក្នុងដំណើរការវិវត្តនិងការអនុវត្តជាក់ស្តែង ធនាគារកណ្តាលជាជំហានៗទទួលបានសិទ្ធិទទួលខុសត្រូវជាសភាផាត់ទាត់មាស និងគ្រប់គ្រងរូបិយវត្ថុជាតិតាមរយៈគណទានជាមាសនៅក្នុងប្រព័ន្ធស្តង់ដារមាស។

នៅក្នុងភារកិច្ចនេះ ធនាគារកណ្តាលមានកាតព្វកិច្ចចម្បងចំនួន២ គឺទី១-ជៀសវាងកុំឲ្យគាំងនូវកិច្ចដំណើរការនៃភាពប្តូរបានរវាងក្រដាសប្រាក់និងមាស ព្រោះកាលនោះ គឺជាសម័យស្តង់ដារមាស និងទី២-គឺការការពារកុំឲ្យមានការរាលដាលនៃការដួលរលំបណ្តាធនាគារពាណិជ្ជ។ ខ្ញុំសូមជម្រាបថា រហូតមកដល់បច្ចុប្បន្ន ធនាគារកណ្តាលនៅលើពិភពលោកនៅតែមានភារកិច្ចដ៏សំខាន់បំផុតចំនួន២ ដែលប្រហាក់ប្រហែលគ្នានឹងភារកិច្ចចម្បងទាំងពីរក្នុងសតវត្សទី១៩ដែរ ដូចជា៖

ទី១៖ ការរក្សាស្ថិរភាព "**តម្លៃរូបិយវត្ថុជាតិ**" គឺទាក់ទងនឹងភារកិច្ចក្នុងការកំណត់ និង ដឹកនាំគោលនយោបាយរូបិយវត្ថុ។

ទី២៖ ការទទួលខុសត្រូវក្នុងការរក្សា "**ស្ថិរភាពប្រព័ន្ធធនាគារ**" ។ ប៉ុន្តែសព្វថ្ងៃនេះ វិធីសាស្ត្រដែលត្រូវបានយកមកប្រើប្រាស់ដើម្បីសម្រេចឲ្យបាននូវភារកិច្ចនេះ គឺទំនើបជាងមុន ហើយនេះរួមបញ្ចូលទាំងការអនុវត្តនូវវិធានការត្រួតពិនិត្យក្នុងកម្រិតខ្ពស់ទៅលើបណ្តាធនាគារផងដែរ។

បច្ចុប្បន្ន ប្រព័ន្ធរូបិយវត្ថុសាកល ឈប់ប្រើប្រាស់ស្តង់ដារមាស និងបានផ្អែកទាំងស្រុង ទៅលើជំនឿសាធារណជនមកលើសមត្ថភាពធនាគារកណ្តាលក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ដែលជាលក្ខខណ្ឌដ៏ចាំបាច់របស់ធនាគារកណ្តាលនាសម័យកាលទំនើបយើងនេះ ហើយដើម្បីបំពេញសេចក្តីរំពឹងទុករបស់សាធារណជននៅក្នុងបរិបទនៃសេដ្ឋកិច្ចសាកលភាវូបនីយកម្មដែលមានការប្រែប្រួលយ៉ាងឆាប់រហ័សនេះ ធនាគារកណ្តាលត្រូវការមន្ត្រីបុគ្គលិកដែលមានពហុជំនាញជាមួយនឹងទស្សនៈថ្មីៗ ដែលអាចបត់បែនទាន់ពេលវេលា។ ម្យ៉ាងទៀត ធនាគារកណ្តាលបាននិងកំពុងប្រឈមទៅនឹងបញ្ហាជាច្រើន រួមមាន ការអនុវត្តគោលនយោបាយរូបិយវត្ថុឲ្យបានល្អ ការរក្សាស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងការផ្តល់ប្រឹក្សាលើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាដើម។

ដូចក្នុងយៗបានដឹងហើយថា ធនាគារកណ្តាល គឺជាស្ថាប័នសាធារណៈនិងស្វយ័តពីរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគ្រឹះស្ថានឯកជននៅក្នុងវិស័យហិរញ្ញវត្ថុ។ លើសពីនេះទៀត នៅក្នុងពិភពនៃប្រព័ន្ធបច្ចេកវិទ្យារីកចម្រើននេះ គោលនយោបាយរបស់ធនាគារកណ្តាលនៅក្នុងទីផ្សារហិរញ្ញវត្ថុនិងសេដ្ឋកិច្ច បានវិវត្តរីកចម្រើនឥតឈប់ឈរ។ ដូច្នេះ ដោយសារតែលក្ខណៈពិសេសរបស់ធនាគារកណ្តាលទាំងនេះហើយ ទើបយើងបន្តអភិវឌ្ឍធនធានមនុស្សឲ្យមានជំនាញគ្រប់ផ្នែក ដើម្បីភាពជោគជ័យរបស់ធនាគារជាតិនៃកម្ពុជា។ ការរៀបចំបើកវគ្គសុក្រឹតការនាថ្ងៃនេះ គឺបានឆ្លុះបញ្ចាំងអំពីការគាំទ្រដល់កម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុង និងដើម្បីផ្តល់ចំណេះដឹងនិងបទពិសោធន៍ក្នុងការបំពេញការងារនៅធនាគារកណ្តាល ជូនដល់មន្ត្រីបុគ្គលិករបស់យើង។

ខ្ញុំសង្ឃឹមថា វគ្គនេះនឹងប្រព្រឹត្តទៅដោយជោគជ័យ ហើយខ្ញុំសូមសំណូមពរឲ្យគណៈកម្មការគ្រប់គ្រងយកចិត្តទុកដាក់ និងធ្វើយ៉ាងណាឲ្យវគ្គសិក្សារបស់យើងដំណើរការទៅដោយរលូន និងមានគុណភាពខ្ពស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាជាទីមេត្រី!**

សរុបមក វគ្គសុក្រឹតការជំនាន់ទី១២នាពេលនេះពិតជាមានសារៈសំខាន់ណាស់ ហើយវាបានកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នា ប្រកបដោយស្មារតីទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និងមន្ត្រីគ្រប់ជាន់ថ្នាក់ដើម្បីបណ្តុះបណ្តាលចំណេះដឹងដល់មន្ត្រីបុគ្គលិកជាពិសេស មន្ត្រីបុគ្គលិកវ័យក្មេងមកពីបណ្តានាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា។ ខ្ញុំសូមអំពាវនាវឲ្យសិក្ខាកាមទាំងអស់ ខិតខំត្រងត្រាប់ ស្តាប់ការឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់យើងដោយយកចិត្តទុកដាក់ ដើម្បីទទួលយកចំណេះដឹងថ្មីៗទៅអនុវត្តការងាររបស់ខ្លួនឲ្យបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់ក្រុមការងារគ្រប់គ្រងវគ្គបណ្តុះបណ្តាលនេះ ដើម្បីជាប្រយោជន៍ និងចូលរួមចំណែកកសាងធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ដែលមានវត្តមាននាពេលនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកវគ្គសុក្រឹតការជំនាន់ទី១២ **ជាផ្លូវការ** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**